

ព្រះជាម្ចាស់គឺជាព្រះវរបិតារបស់ខ្ញុំ



(7)

នេះគឺជាពាក្យរបស់លោក ដេវក ព្រីនស៍
ដែលបានដកស្រង់ពីព្រះបន្ទូលនៃព្រះសម្រាប់លោកអ្នក។

> ដូច្នេះ ចូរអធិស្ឋានបែបយ៉ាងនេះវិញថា៖
> «ឱព្រះវរបិតានៃយើងខ្ញុំ ដែលគង់នៅស្ថានសួគ៌អើយ
> សូមឲ្យព្រះនាមទ្រង់បានបរិសុទ្ធ»។ [ម៉ាថាយ ៦:៩]

មានពាក្យដ៏សំខាន់បំផុតពីរនៅក្នុងគំរូនៃការអធិស្ឋាន
ពីរពាក្យដំបូងនោះគឺ៖ «ព្រះវរបិតានៃ(របស់)យើងខ្ញុំ»។

ដំបូងបង្អស់ យើងត្រូវដឹងថាយើងអាចអធិស្ឋានទៅព្រះវរបិតាបាន។
ពិភពលោកនេះមិនមែនគ្រាន់តែជាបណ្តុំនៃកាល:ទេស:ដែលគ្មានរបៀបនោះទេ
វាក៏មិនមែនគ្រាន់តែជារបស់លេងមួយនៃអំណាចរបស់សម្ភារនិយមដែលមាននរណាម្នាក់អាចយល់ ឬគ្រប់គ្រងបាននោះដែរ។
យើងប្រសើរជាងគ្រឿងម៉ាស៊ីន។ យើងក៏ប្រសើរជាងសន្ទះចិត្តដែរ។
យើងកំពុងតែរស់នៅ ជាមនុស្សដែលកំពុងតែដកដង្ហើម
ត្រូវបានបង្កើតឡើងឲ្យមានលក្ខណៈដូចជាព្រះដែលទ្រង់ស្រឡាញ់យើង និងយកព្រះហឫទ័យទុកដាក់ចំពោះយើង
ហើយចង់ធ្វើជាព្រះវរបិតារបស់យើង។

នៅពីក្រោយអ្វីៗទាំងអស់
នៅក្នុងលោកិយនេះមិនមែនគ្រាន់តែជាអំណាចដែលគ្មានជីវិតនោះទេ
ក៏មិនមែនជាឫទ្ធិអំណាចដ៏អាថកំបាំងដែរ
ប៉ុន្តែជាបុគ្គលដែលមានជីវិតដ៏អស់កល្បជានិច្ច
ហើយទ្រង់ជាព្រះវរបិតារបស់យើង។ ទ្រង់ជាអ្នកគ្រប់គ្រង។
ទ្រង់បានបង្កើតពិភពលោក។ ទ្រង់បានបង្កើតយើង។
ទ្រង់បានដាក់យើងនៅក្នុងពិភពលោក(លោកិយ)។ យើងនៅទីនេះ
ពីព្រោះទ្រង់បានដាក់យើងនៅទីនេះ។

ទាំងអស់នេះធ្វើឲ្យមានភាពខុសប្លែកគ្នាចំពោះរបៀបដែលយើងមានអារម្មណ៍អំពីជីវិត អំពីពិភពលោក អំពីស្ថានភាព និងកាល:ទេស:។
យើងមិនចាំបាច់ត្រូវនៅឯកាទេ។
យើងមិនចាំបាច់ត្រូវមានអសន្តិសុខទេ។
អ្វីគ្រប់យ៉ាងគឺស្ថិតនៅក្នុងព្រះហស្តរបស់ព្រះវរបិតា។

ហើយទ្រង់គឺជាព្រះវរបិតារបស់យើង ទ្រង់មានកូនជាច្រើន។
យើងគ្រាន់តែជាកូនម្នាក់នៅក្នុងចំណោមកូនៗទាំងនោះ។
យើងត្រូវចាំថា អ្នកផ្សេងទៀត ក៏ជាកូនរបស់ទ្រង់ដែរ។
យើងត្រូវគិតអំពីពួកគេ យើងត្រូវមើលថែគ្នាទៅវិញទៅមក។
យើងត្រូវមានចិត្តសប្បុរសចំពោះគ្នាទៅវិញទៅមក។

© 1970 — Derek Prince Ministries - International®

យើងត្រូវផ្តល់នូវការផ្គត់ផ្គង់ឲ្យគ្នាទៅវិញទៅមក។
យើងត្រូវបង្ហាញក្តីស្រឡាញ់
និងក្តីមេត្តាចំពោះគ្នាទៅវិញទៅមកដូចដែលទ្រង់បង្ហាញដល់យើង។
សូមចាំថា ទ្រង់គឺជាព្រះវរបិតារបស់យើង។

: WD-WFTW-007-KHM
: 24 Feb 2026
: derekprince.com/km/resources

